អាជ្ញាធរអប្សរា
APSARA
N°...................

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION ROI

# សេចក្តីជូនដំណឹង

## ស្តីពី

## ការសុំសាងសង់ ឬ ជួសជុលគ្រប់គ្រប់ប្រភេទ នៅក្នុងតំបន់ការពារ ទី១ និង ទី២ នៃឧទ្យានអង្គរ

អាជ្ញាធរអប្សរាសូមជូនដំណឹងដល់សាធារណជនបានជ្រាបថា: ប្រជាពលរដ្ឋដែលមានលំនៅដ្ឋាន និងរស់នៅក្នុងតំបន់ការពារទី១ និង ទី២ យូរលង់មកហើយ អាចរុះរើ ជួសជុលផ្ទះចាស់ទ្រុឌទ្រោម ឬសាងសង់ថ្មី ជំនួសផ្ទះចាស់បាន តែមិនអនុញ្ញាតឱ្យសាងសង់ផ្ទះថ្មីបន្ថែមទេ។ រាល់ការសាងសង់ ឬជួសជុលអគារគ្រប់ប្រភេទ ឬ ការរុះរើអគារបុរាណដែលមានតម្លៃផ្នែកស្ថាបត្យកម្ម ឬ ប្រវត្តិសាស្ត្រ ដែលស្ថិតនៅក្នុងតំបន់ការពារ ទី១ និង ទី២ នៃឧទ្យានអង្គរ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរអប្សរាជាចាំបាច់។

សាធារណជនអាចអញ្ជើញសាកសួរពត៌មាន ដែលទាក់ទងនឹងរឿងនេះ នៅនាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី២ នៃអាជ្ញាធរអប្សរា ដែលមានទីតាំងស្ថិតក្នុងបរិវេណអភិរក្សដ្ឋានអង្គរ ក្នុងភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប រាល់ពេលម៉ោងនៃថ្ងៃធ្វើការ។

ពាក្យសុំសាងសង់ ឬជួសជុល ត្រូវធ្វើតាមគំរូលិខិត ដែលអាជ្ញាធរអប្សរា នឹងផ្តល់ជូន ដោយមានចុះហត្ថលេខាពីអ្នកសុំ និងមានបញ្ជាក់ពីសាលាឃុំ និងសាលាស្រុក។ រាល់ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវបញ្ជីគ្រួសារ ១ច្បាប់ (ថតចម្លង) និងប័ណ្ណកាន់កាប់ដីធ្លី ១ច្បាប់ (ថតចម្លង)។ ពាក្យស្នើសុំត្រូវដាក់នៅរដ្ឋបាលកណ្តាលនៃអាជ្ញាធរអប្សរា។ សមត្ថកិច្ចអាជ្ញាធរអប្សរាអាចជួយតាមផ្លូវបច្ចេកទេស ណែនាំគូររូបភាពសំណង់ឱ្យមានលក្ខណៈជាស្ថាបត្យកម្មខ្មែរ ជូនដល់អ្នកសុំ។ បន្ទាប់មកអាជ្ញាធរអប្សរា នឹងបញ្ជូនទៅសុំយោបល់ពីក្រសួង សមត្ថកិច្ចពាក់ព័ន្ធនានាក្នុងខេត្ត និងវាយតម្លៃសរុប ធ្វើសេចក្តីសំរេចជាស្ថាពរ ឱ្យបានក្នុងកំរិត ៣០ ថ្ងៃធ្វើការ គឺរាប់ពីថ្ងៃដែលចេញបង្កាន់ដៃទទួលពាក្យសុំអនុញ្ញាត។ អ្នកសុំមិនតម្រូវឱ្យបង់ប្រាក់លើសេវាកម្មទាំងអស់នេះទេ។

សាធារណជនណា ដែលធ្វើការសាងសង់ ឬ ជួសជុលអគារ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរអប្សរា នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

ភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៤
អគ្គនាយកអាជ្ញាធរអប្សរា

ប៊ិន. ណារិទ្ធ


អាជ្ញាធរជាតិដើម្បីការពារ និងរៀបចំតំបន់អង្គរ
AUTORITE POUR LA PROTECTION DU SITE ET L'AMENAGEMENT DE LA REGION D' ANGKOR

PHNOM PENH :
187, Pasteur St, Chaktomuk, Daun Penh
Téléphone : (855-23) 720 315, 721 150
Télécopie : (855-23) 990 185

Website : http://www.autoriteapsara.org
E-mail : apsara-admin@camnet.com.kh

SIEM REAP :
Conservation d'Angkor
Téléphone : (855-63) 760 080
Télécopie : (855-63) 964 819